ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២០ លេខ៧០ ត្រីមាសទី០៣ ឆ្នាំ២០២០

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៨-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩២០ ស្តីពី ការផ្តល់គោរមងារអ្នកស្រី **ស្រី ណារួម** ជា ឧកញ៉ា | ៨៥៦៩ |
| ២៨-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩២១ ស្តីពី ការផ្តល់គោរមងារលោក **គិត សែនពិសិដ្ឋ** ជា ឧកញ៉ា | ៨៥៧០ |
| ២៩-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩២២ ស្តីពី ការតម្លើងថ្នាក់លោក **ទង់ សែនទិចិត្រ** នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ | ៨៥៧១ |
| ២៩-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩២៣ ស្តីពី ការផ្តល់គោរមងារលោក **មុំ សុផាន់ណា** ជា ឧកញ៉ា | ៨៥៧២ |
| ២៩-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩២៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់គណៈកម្មា-ធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត | ៨៥៧៣ |
| ២៩-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩២៦ ស្តីពី ការតែងតាំងឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** ជា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន | ៨៥៧៨ |
| ២៩-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩២៧ ស្តីពី ការតែងតាំងមុខតំណែងឯកឧត្តម **ប៉ាន សុបណ្ឌិត** ជាអនុរដ្ឋលេខាធិការក្រសួងផែនការ | ៨៥៧៩ |
| ២៩-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩២៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈលោកជំទាវ **សាយ សំអាត** ជាប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ស្ថិតក្រោមធនាគារជាតិនៃកម្ពុជា | ៨៥៨០ |
| ២៩-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩៣០ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា អម ក្រសួងយុត្តិធម៌ ៣៨ រូប | ៨៥៨១ |
| ២៩-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩៣១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឈិន តឺលន់ (CHEN DELUN)** ជនជាតិចិន សញ្ជាតិចិន | ៨៥៨៤ |
| ២៩-៨-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩៣២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឈិន ឈីងឈាំង (CHEN QINGQIANG)** ជនជាតិចិន សញ្ជាតិចិន | ៨៥៨៥ |
| ៣-៩-២០២០ | -ព្រះរាជក្រឹត្យ នស/រកត/០៩២០/៩៣៤ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តម ឧត្តម-សេនីយ៍ឯក **តោ ម៉ូ** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក | ៨៥៨៦ |

៣-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/៩៣៥ ស្ដីពី ការផ្ដល់នីតិសម្បទាឡើងវិញឱ្យឈ្មោះ **សុន ន័យ** ភេទ ប្រុស ដែលត្រូវបានហាមឃាត់មិនឱ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ៨៥៨៧

៣-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/៩៣៦ ស្ដីពី ការផ្ដល់នីតិសម្បទាឡើងវិញឱ្យឈ្មោះ **តាង គឹមឈុន** ភេទ ប្រុស ដែលត្រូវបានហាមឃាត់មិនឱ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ៨៥៨៨

៣-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/៩៣៧ ស្ដីពី ការផ្ដល់នីតិសម្បទាឡើងវិញឱ្យឈ្មោះ **ម៉ា សាម៉ុន** ភេទ ប្រុស ដែលត្រូវបានហាមឃាត់មិនឱ្យធ្វើសកម្មភាពនយោបាយ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ៨៥៨៩

៣-៩-២០២០ -ព្រះរាជក្រឹត្យ នស/រកត/០៩២០/៩៣៨ ស្ដីពី ការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ **ប៉ុន ស៊ីណាត** ភេទ ស្រី អាយុ ៥២ ឆ្នាំ ពីបទឆបោក មានស្ថានទម្ងន់ទោស (នាំមនុស្សឱ្យចូលក្របខ័ណ្ឌយោធា នគរបាល និងគ្រូបង្រៀន) ៨៥៩០

## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១៤-៨-២០២០ -អនុក្រឹត្យលេខ ១២៩ អនក្រ.បក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ ៨៥៩១

២៥-៨-២០២០ -អនុក្រឹត្យលេខ ១៣០ អនក្រ.បក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអន្តរក្រសួងស្ដីពី សុខភាពសិក្សា ៨៥៩៨

២៦-៨-២០២០ -អនុក្រឹត្យលេខ ១៣១ អនក្រ.បក ស្ដីពី ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០២១ ៨៦០៣

១៦-៧-២០២០ -អនុក្រឹត្យលេខ ៦៧៤ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨៦០៥

## III~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣១-១២-២០១៩ -ប្រកាសលេខ ១៤៧៦ សហវ.អថ ស្ដីពី ការប្រគល់កាតព្វកិច្ចប្រមូលចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ (*តទៅ រាជកិច្ចលេខ៧១*) ៨៦៧៦

### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

២៤-២-២០២០ -ប្រកាសលេខ ០៩៤ ឧស.កឧ.ប្រក ០២ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ិន លាន ស៊ិន អេឡាស្ទិក & ស្រ្ទីង (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតគ្រឿងបន្សំ (សម្លៀកបំពាក់ ស្បែកជើង និងកាបូប) ៨៦៩២

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/៩៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ត្រាស់បង្គាប់**

ផ្តល់គោរមងារ :

អ្នកស្រី **ស្រី ណារូម**

ជា

**ឧកញ៉ា**

នរោត្តម សីហមុនី

៧រស. ២០០៥-៩៤៧

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/៩៤១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោក **គិត សែនពិសិដ្ឋ**

ជា

**ឧកញ៉ា**

ចារស.២០០៥.៩៤៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/៩៤៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងថ្នាក់ **លោក ខង់ សែនមិថិត្រា** អត្តលេខ ២៤២៣ ពីឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ៣ មកជា ថ្នាក់លេខ២ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ៕

នរោត្តម សីហមុនី

៣៧៣.២០០៨.៩៤៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២០*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/៩២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

## ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោក មុំ សុផាន់ណា

ជា

**ឧកញ៉ា**

នរោត្តម សីហមុនី

៣៧៣.២០០៥.៩៤៥

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/៩៤៤

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ

## របស់គណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិសម្រាប់ការសិក្សាពេញមួយជីវិត ដែលសរសេរជាអក្សរកាត់ថា [illegible] ដើម្បីជាយន្តការសម្របសម្រួលតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងជួយរាជរដ្ឋាភិបាលអំពី [illegible]ការសិក្សាពេញមួយជីវិត ឱ្យឆ្លើយតបទៅនឹងច្បាប់ស្តីពីការអប់រំនិងគោលនយោបាយជាតិស្តីពីការសិក្សា[illegible]បជីវិត

## ជំពូកទី២

## សមាសភាពរបស់គ.ជ.ស.ជ.

**មាត្រា២ ..**

**គ.ជ.ស.ជ.**មានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| - ឧបនាយករដ្ឋមន្ត្រី១រូប | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធានប្រចាំការ |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ១រូប | សមាជិក |
| - អគ្គលេខាធិការនៃ**គ.ជ.ស.ជ.** | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ**គ.ជ.ស.ជ.**ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់គ.ជ.ស.ជ.

**មាត្រា៣ .-**

**គ.ជ.ស.ជ.**មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលលើការអនុវត្តគោលនយោបាយជាតិស្ដីពីការសិក្សាពេញមួយជីវិត និងមានភារកិច្ចដូចខាងក្រោម៖

- កសាងនិងផ្សព្វផ្សាយផែនការសកម្មភាពជាតិសម្រាប់ការសិក្សាពេញមួយជីវិត
- លើកសំណើជូនរាជរដ្ឋាភិបាលក្នុងការរៀបចំក្របខ័ណ្ឌច្បាប់ យន្តការ និងដាក់ចេញនូវវិធានការចាំបាច់នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សម្រាប់គាំទ្រការអនុវត្តគោលនយោបាយជាតិ
- ជំរុញនិងសម្របសម្រួលការផ្ដល់សេវាអប់រំក្រៅប្រព័ន្ធនិងអប់រំមិនផ្លូវការដល់ពលរដ្ឋគ្រប់រូប ឱ្យទទួលបានអក្ខរពុទ្ធិ លេខពុទ្ធិ បំណិនបច្ចេកទេសវិជ្ជាជីវៈតាមគ្រប់រូបភាព និងមានលទ្ធភាពសិក្សាពេញមួយជីវិត
- រៀបចំនិងអភិវឌ្ឍកម្មវិធីសិក្សាពេញមួយជីវិតឱ្យសម្បូរបែប និងមានភាពបត់បែន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ទីកន្លែងសិក្សា និងមជ្ឈមណ្ឌលសិក្សា
- លើកកម្ពស់ការបណ្ដុះបណ្ដាលនិងលើកកម្ពស់សមភាពយេនឌ័រ សមធម៌ និងបរិយាបន្ន
- ជំរុញនិងលើកទឹកចិត្តពលរដ្ឋឱ្យមានវប្បធម៌សិក្សាពេញមួយជីវិត
- សម្របសម្រួលនិងជំរុញក្រសួង ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិក្នុងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិសម្រាប់ការសិក្សាពេញមួយជីវិត
- លើកកម្ពស់ការអប់រំពេញមួយជីវិតតាមប្រព័ន្ធបច្ចេកវិទ្យា
- ជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការចូលរួមផ្ដល់សេវានិងគាំទ្រការសិក្សាពេញមួយជីវិត
- លើកសំណើជូនរាជរដ្ឋាភិបាលក្នុងការកែសម្រួលគោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់ការសិក្សាពេញមួយជីវិត
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយនិងផែនការសកម្មភាពជាតិសម្រាប់ការសិក្សាពេញមួយជីវិតនៅតាមក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ
- ធ្វើរបាយការណ៍អំពីលទ្ធផលវឌ្ឍនភាពក្នុងការអនុវត្តគោលនយោបាយនិងផែនការសកម្មភាពជាតិសម្រាប់ការសិក្សាពេញមួយជីវិតជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់គ.ជ.ស.ជ.

**មាត្រា៤ .-**

**គ.ជ.ស.ជ.**ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធាន**គ.ជ.ស.ជ.**អាចកោះប្រជុំជាវិសាមញ្ញ។ **គ.ជ.ស.ជ.**ត្រូវធ្វើការបូកសរុបរបាយការណ៍ក្នុងមួយឆ្នាំម្ដង និងធ្វើរបាយការណ៍ជូនអង្គប្រជុំ**គ.ជ.ស.ជ.** ក្រោមអធិបតីភាពរបស់ប្រធាន អំពីលទ្ធផលនៃការអនុវត្តកម្មវិធី ព័ត៌មានដែលត្រូវសម្របសម្រួលនិងអនុសាសន៍ដែល**គ.ជ.ស.ជ.** ត្រូវដាក់ចេញ។

របៀបរបបនៃការប្រជុំរបស់**គ.ជ.ស.ជ.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ដែលសម្រេចដោយ**គ.ជ.ស.ជ.**។

**មាត្រា៥ .-**

**គ.ជ.ស.ជ.**មានសិទ្ធិទាក់ទងក្រសួង ស្ថាប័ននានា អង្គការសង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានា ដែលពុំមានចែងក្នុងមាត្រា២នៃព្រះរាជក្រឹត្យនេះ ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬចូលរួមជាអ្នកសង្កេតការណ៍តាមការអញ្ជើញរបស់**គ.ជ.ស.ជ.**។

**មាត្រា៦ .-**

**គ.ជ.ស.ជ.**មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន និងមានទីតាំងនៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរបស់**គ.ជ.ស.ជ.** ត្រូវកំណត់ដោយអនុក្រឹត្យ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧ .-**

**គ.ជ.ស.ជ.**អាចបង្កើតគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់ ដើម្បីជួយការងារពាក់ព័ន្ធការសិក្សាពេញមួយជីវិត។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការជំនាញ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន**គ.ជ.ស.ជ.**។

**គ.ជ.ស.ជ.**ត្រូវប្រើប្រាស់យន្តការដែលមានស្រាប់នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន**គ.ជ.ស.ជ.**។

**មាត្រា៨ .-**

ប្រធាន**គ.ជ.ស.ជ.**មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន តំណាងប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ឬដៃគូអភិវឌ្ឍពាក់ព័ន្ធ ដើម្បីជួយការងារ**គ.ជ.ស.ជ.** និងអគ្គលេខាធិការដ្ឋាន។

**មាត្រា៩ .-**

**គ.ជ.ស.ជ.**មានរូបសញ្ញានិងមានត្រាដោយឡែករបស់ខ្លួន ដែលកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ប្រភពធនធានរបស់គ.ជ.ស.ជ.

**មាត្រា១០ .-**

ការចំណាយសម្រាប់ដំណើរការរបស់**គ.ជ.ស.ជ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា។

**គ.ជ.ស.ជ.**មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត តាមនីតិវិធីច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។ ៕

ថ្ងៃ *សៅរ៍ ១១កើត* ខែ *ភទ្របទ* ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែ *សីហា* ឆ្នាំ២០២០

*នស/រកត/០៨២០/៩៤៦*

*នរោត្តម សីហមុនី*

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/ ៩២៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្តមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០៦១៨ / ០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** ជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

[illegible]

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០២០*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/៩៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងមុខតំណែងឯកឧត្តម **ប៉ាន សុបណ្ណរិត** ជាអនុរដ្ឋលេខាធិការក្រសួងផែនការ។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ពរស.២០០៥.៩៤១

នសីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/៩២៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្តមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា៥៧ នៃច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈ លោកជំទាវ **សាយ សំអាត** ជាប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ស្ថិតក្រោមធនាគារជាតិនៃកម្ពុជា ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៧៣.២០០៨.៩៥០

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/៩៣០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សាអមក្រសួងយុត្តិធម៌ ៣៨ រូប:

១-ឯកឧត្តម **រស់ មុនិន្ទ:** មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បំណាច់មុខងារ

២-ឯកឧត្តម **ឃុត កែវសុត្ថា** មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បំណាច់មុខងារបន្ថែមលើមុខងារបច្ចុប្បន្ន

៣-ឯកឧត្តម **លី សុខឡាយ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បំណាច់មុខងារ

| | | | |
|---|---|---|---|
| ៤-ឯកឧត្តម | **អ៊ុំ រតនា** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ៥-ឯកឧត្តម | **ខៀវ ភក្តី** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ៦-ឯកឧត្តម | **សិទ្ធិ រតនា** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ៧-ឯកឧត្តម | **គីម សុជាតិ** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ៨-ឯកឧត្តម | **ធួន សុធា** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ៩-ឯកឧត្តម | **ទី វណ្ណដេត** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ១០-លោកជំទាវ | **ជា សុភន្ទូន** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ១១-ឯកឧត្តម | **ម៉ែន មុនីតារា** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ១២-ឯកឧត្តម | **ហួន វិទ្យា** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ១៣-ឯកឧត្តម | **កែវ ពេជ្ជនៈ** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ១៤-ឯកឧត្តម | **ចាំង សុជាតិ** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ១៥-ឯកឧត្តម | **ប៊ុន ធី** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ១៦-ឯកឧត្តម | **ជា តារ៉ា** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ១៧-ឯកឧត្តម | **ខៀវ រដ្ឋា** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ១៨-ឯកឧត្តម | **អាំង សុវណ្ណារ៉ា** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ១៩-ឯកឧត្តម | **ខាត់ វិចិត្រ** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ២០-ឯកឧត្តម | **ប៉ូច ពៅ** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ២១-ឯកឧត្តម | **ផន ឈៀងឡេង** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ២២-ឯកឧត្តម | **ឡេង សុខហេង** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ២៣-ឯកឧត្តម | **អ៊ឹម រចនា** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ២៤-ឯកឧត្តម | **អ៊ួន ឡាង** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ២៥-ឯកឧត្តម | **ស៊ឹង លីហេង** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ២៦-ឯកឧត្តម | **ឃឹម ខេម៉ា** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |
| ២៧-ឯកឧត្តម | **សៅ សុវណ្ណារ៉ា** | មានឋានៈស្មើ អគ្គនាយក | ដោយពុំទទួលប្រាក់បំណាច់មុខងារ |

* ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២៨-ឯកឧត្តម **លាស់ គឹមឃោង** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

២៩-ឯកឧត្តម **ខ៉ាន់ចាន់ ពៅដារ៉ា** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

៣០-លោកជំទាវ **សារី ម៉ារីយ៉ា** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

៣១-ឯកឧត្តម **ញឹម សុខឿន** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

៣២-ឯកឧត្តម **នី ទិចិត្រ** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

៣៣-ឯកឧត្តម **ទ៉េង បញ្ញា** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

៣៤-ឯកឧត្តម **ឃុ លីមហួត** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

៣៥-ឯកឧត្តម **យ៉ុន ម៉ុនណា** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

៣៦-ឯកឧត្តម **ឃិច ពុទ្ធិកោសល្យ** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

៣៧-ឯកឧត្តម **សៅ សម្បត្តិ** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

៣៨-ឯកឧត្តម **លី សុវណ្ណបញ្ញា** មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៧៧.២០០៥.៩៥៤

ន សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/ ៩៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឈិន តឺលន់** ( CHEN DELUN ) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩០ នៅខេត្តហ៊្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៣៧.២០០៥.៩៥៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០*

នសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨២០/ ៩៣២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឈិន ឈីងឈាំង** (CHEN QINGQIANG) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៨៩ នៅខេត្តហ៊្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៧.២០០៥.៩៥៤

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៩២០/ ៩៣៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួល សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើក ផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម ឧត្តមសេនីយ៍ឯក **សោ ម៉ូ** អត្តលេខ ៣១០៦០ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

៣៧.២០០៩.៩៥៦

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០២០*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៩២០/ ៩៣៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៤៥ថ្មី(ស្ទួន) នៃច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្តល់នីតិសម្បទាឡើងវិញឲ្យឈ្មោះ សុន ឆ័យ ភេទ ប្រុស កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៥៦ ដែលត្រូវបានហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំ តាមអំណាចសាលដីកាលេខ: ៣៤០(ផ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ន.សីហមុនី

ពរក.២០០៩.៩៥៧

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៩២០/៩៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៤៥ថ្មី(ស្ទួន) នៃច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្តល់នីតិសម្បទាឡើងវិញឲ្យឈ្មោះ តាវ គឹមឈុន ភេទ ប្រុស កើតថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៥២ ដែលត្រូវបានហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំ តាមអំណាចសាលដីកាលេខៈ ៣៤០(ឆ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៧-២០០៩.៩៥៩

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២០*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា

បានមួយគ្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៩២០/៩៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឲ្យច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១៩/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៤៥ថ្មី(ស្ទួន) នៃច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្តល់នីតិសម្បទាឡើងវិញឲ្យឈ្មោះ វ៉ា សាម៉ុន កេទ ប្រុស កើតថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥០ ដែលត្រូវបានហាមឃាត់មិនឲ្យធ្វើសកម្មភាពនយោបាយសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំ តាមអំណាចសាលដីកាលេខៈ ៣៤០(ឧ) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់តុលាការកំពូល។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៧.២០០៩.៩៥៩

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២០*

**នរោត្តម សីហមុនី**

បានយកសេចក្តីគោរពក្រាបបង្គំទូលថ្វាយ ... 

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៩២០/៩៣៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានលើកលែងទោសឱ្យទណ្ឌិតឈ្មោះ ប៉ុន ស៊ីណាត ហៅ ទ្រី ណាត ភេទស្រី អាយុ ៥២ឆ្នាំ ពីបទឆបោកមានស្ថានទម្ងន់ទោស( នាំមនុស្សឱ្យចូលក្របខ័ណ្ឌយោធា នគរបាល និងគ្រូបង្រៀន ) ហើយត្រូវបានតុលាការយោធាសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន០២( ពីរ )ឆ្នាំ តាមអំណាចសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ០១០ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ របស់តុលាការយោធា ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

៣៧៧.២០០៩.៩២០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០២០*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ១៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២០/៦៦១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអ្នកច្បាប់
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់។

## ជំពូកទី២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ក.ប.ច.

**មាត្រា២ .-**

អគ្គលេខាធិការដ្ឋាន **ក.ប.ច.** មានតួនាទីជាសេនាធិការឱ្យ **ក.ប.ច.** និងមានភារកិច្ចដូចតទៅ៖

- សម្របសម្រួលនិងទទួលបន្ទុកការងាររដ្ឋបាលទូទៅប្រចាំថ្ងៃរបស់ **ក.ប.ច.**
- គ្រប់គ្រងនិងដឹកនាំការងារប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន **ក.ប.ច.**
- ទទួលបន្ទុករៀបចំ គ្រប់គ្រង និងចាត់ចែងថវិកា **ក.ប.ច.**
- ចាត់ចែងនិងគ្រប់គ្រងសម្ភារៈបរិក្ខាររបស់ **ក.ប.ច.**
- គ្រប់គ្រងឯកសារនិងលិខិតចេញចូល
- ស្រាវជ្រាវនិងរៀបចំចងក្រងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតតាមប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំនិងសម្របសម្រួលរាល់កិច្ចប្រជុំរបស់ **ក.ប.ច.** និងសិក្ខាសាលានានា
- រៀបចំការផ្លាស់ប្តូរបទពិសោធនិងការបណ្តុះបណ្តាល
- គ្រប់គ្រងបណ្ណាល័យនិងបោះពុម្ពព្រឹត្តិបត្ររបស់ **ក.ប.ច.**
- គ្រប់គ្រងការងារបុគ្គលិកអគ្គលេខាធិការដ្ឋាន **ក.ប.ច.**
- រៀបចំបែបបទជូន **ក.ប.ច.** លើការងារសម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ដែលពាក់ព័ន្ធដើម្បីរៀបចំសេចក្តីព្រាងលិខិតឆ្លើយតបរបស់រាជរដ្ឋាភិបាលទៅនឹងសំណួរឬសំណើរបស់រដ្ឋសភា
- រៀបចំបែបបទជូន **ក.ប.ច.** លើការបញ្ជូនសេចក្តីព្រាងច្បាប់ទៅស្ថាប័ននីតិប្បញ្ញត្តិ
- រៀបចំបែបបទជូន **ក.ប.ច.** លើការងារសម្របសម្រួលរៀបចំសមាសភាពតំណាងរាជរដ្ឋាភិបាលទៅការពារសេចក្តីព្រាងច្បាប់ឬទៅបំភ្លឺនៅស្ថាប័ននីតិប្បញ្ញត្តិ
- រៀបចំបែបបទជូន **ក.ប.ច.** ដើម្បីគោរពជូននាយករដ្ឋមន្ត្រីចុះហត្ថលេខាលើលិខិតបទដ្ឋានគតិយុត្ត ឬដើម្បីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- រៀបចំបែបបទជូន **ក.ប.ច.** ដើម្បីគោរពជូននាយករដ្ឋមន្ត្រីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រសូមឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់
- ជួយ **ក.ប.ច.** លើការងារផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- ចាត់តាំងមន្ត្រីអគ្គលេខាធិការដ្ឋាន **ក.ប.ច.** ចូលរួមប្រជុំនិងធ្វើរបាយការណ៍គ្រប់កិច្ចប្រជុំ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាពការងាររបស់ **ក.ប.ច.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **ក.ប.ច.**។

**មាត្រា៣ .-**

អគ្គលេខាធិការដ្ឋាន **ក.ប.ច.** ដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប និងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការនិងអគ្គលេខាធិការរងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

អគ្គលេខាធិការរងបំពេញភារកិច្ចតាមការបែងចែកការងារពីអគ្គលេខាធិការ។

**មាត្រា៤ .-**

អគ្គលេខាធិការដ្ឋាន **ក.ប.ច.** មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដំណើរការការងារប្រចាំថ្ងៃ។

**មាត្រា៥ .-**

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាន **ក.ប.ច.** គឺជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈនៃទីស្ដីការគណៈរដ្ឋមន្ត្រី។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **ក.ប.ច.** អាចស្នើសុំមន្ត្រីជាប់កិច្ចសន្យាឱ្យមកបំពេញការងារបាន។

**មាត្រា៦ .-**

អគ្គលេខាធិការដ្ឋាន **ក.ប.ច.**មានរចនាសម្ព័ន្ធដូចតទៅៈ

- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញកិច្ច
- នាយកដ្ឋានទទួលបន្ទុកកិច្ចការទាក់ទងជាមួយនឹងស្ថាប័ននីតិប្បញ្ញត្តិ
- នាយកដ្ឋានទទួលបន្ទុកកិច្ចការច្បាប់ពាក់ព័ន្ធនឹងការងារផ្ទៃក្នុងនិងការបរទេស
- នាយកដ្ឋានទទួលបន្ទុកកិច្ចការច្បាប់ពាក់ព័ន្ធនឹងការងារសេដ្ឋកិច្ចនិងសង្គម
- នាយកដ្ឋានទទួលបន្ទុកកិច្ចការច្បាប់ពាក់ព័ន្ធនឹងការងារផលិតកម្ម ធនធានធម្មជាតិ ដឹកជញ្ជូន និងសំណង់។

**មាត្រា៧ .-**

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **ក.ប.ច.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៨ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋាននានារបស់អគ្គលេខាធិការដ្ឋាន **ក.ប.ច.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី។

## ជំពូកទី៣
## ភារកិច្ចរបស់នាយកដ្ឋាននីមួយៗ

**មាត្រា៩ .-**

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញកិច្ចមានភារកិច្ចដូចតទៅៈ

- សម្របសម្រួលផ្នែករដ្ឋបាល
- រៀបចំបែបបទទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអង្គការអន្តរជាតិនានា
- រៀបចំនិងសម្របសម្រួលរាល់កិច្ចប្រជុំរបស់ **ក.ប.ច.** សិក្ខាសាលា និងការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- រៀបចំការផ្លាស់ប្ដូរបទពិសោធនិងការបណ្ដុះបណ្ដាល
- គ្រប់គ្រងរាល់ឯកសារផ្សេងៗនិងបណ្ណាល័យ
- រៀបចំ ចងក្រង និងបោះពុម្ពផ្សាយព្រឹត្តិបត្រ
- គ្រប់គ្រងបណ្ដាញព័ត៌មានវិទ្យារបស់ **ក.ប.ច.**
- ពិនិត្យវេយ្យាករណ៍និងអក្ខរាវិរុទ្ធគ្រប់ឯកសារក្នុងក្របខ័ណ្ឌការងាររបស់ **ក.ប.ច.**
- ផ្ដល់ការគាំទ្រផ្នែកសម្ភារៈ បរិក្ខារ
- ជួយអគ្គលេខាធិការលើការងារគ្រប់គ្រងបុគ្គលិក
- រៀបចំនិងអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ
- គ្រប់គ្រងទ្រព្យសម្បត្តិ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌ
